នស/រកត/០៩២៣/៤០៦៤

# ព្រះរាជក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ព្រះរាជក្រឹត្យនេះមានគោលដៅបង្កើត និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់ ក្នុងគោលបំណងលើកស្ទួយរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីប្រមូលផ្ដុំចូលនៃទស្សនៈពហុគំនិតជាប្រយោជន៍ដល់ការស្ថាបនាជាតិ។

**មាត្រា២ ..**

ត្រូវបានបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្ដល់យោបល់ ដោយមានសមាសភាពពីគណបក្សនយោបាយទាំងឡាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងគណបក្សនយោបាយផ្សេងទៀតដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

ការចូលរួមរបស់គណបក្សនយោបាយអនុលោមតាមកថាខណ្ឌទី១ ខាងលើ គឺឈរលើគោលការណ៍ស្ម័គ្រចិត្តរបស់ថ្នាក់ដឹកនាំគណបក្សនយោបាយនីមួយៗ និងដោយអនុលោមតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ទទួលបានបុព្វសិទ្ធិជាគណបក្សស្ថាបនិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភានេះ ក្នុងលក្ខខណ្ឌដែលគណបក្សនយោបាយនោះបានដាក់ពាក្យស្នើសុំជាផ្លូវការក្នុងរយៈពេល ២សប្តាហ៍ បន្ទាប់ពីការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ និងទទួលបានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី សម្រាប់ការតែងតាំងជាសមាសភាពដំបូងនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដោយអនុលោមតាមព្រះរាជក្រឹត្យនេះ។

ក្រៅពីគណបក្សស្ថាបនិកដូចមានចែងក្នុងកថាខណ្ឌទី៣ ខាងលើ គណបក្សនយោបាយផ្សេងទៀត ទាំងគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ទាំងគណបក្សនយោបាយដែលមិនបានចូលរួមក្នុងការបោះឆ្នោតនេះ ប៉ុន្តែ បានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ អាចស្នើសុំចូលរួមជាសមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បាន ដោយត្រូវដាក់ពាក្យស្នើសុំជាផ្លូវការ និងត្រូវមានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី។

**មាត្រា៣.-**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ជាយន្តការពិគ្រោះនិងផ្តល់យោបល់របស់គណបក្សនយោបាយជូនរាជរដ្ឋាភិបាល ក្រៅក្របខណ្ឌសភា ក្នុងគោលដៅលើកស្ទួយប្រសិទ្ធភាពការងារ ដើម្បីជាប្រយោជន៍ដល់ការបម្រើសេវាជូនប្រជាជន និងការអភិវឌ្ឍសង្គមជាតិ ប្រកបដោយសក្តានុពល។

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានអាណត្តិដូចអាណត្តិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

## ជំពូកទី២
## ការរៀបចំឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

**មាត្រា៤.-**

គណបក្សនយោបាយដែលចូលរួមជាសមាសភាពនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដោយបានបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវបញ្ជូនប្រតិភូ ដើម្បីចូលរួមជាសមាសភាពនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដូចមានកំណត់ក្នុងមាត្រា៥ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៥.-**

ប្រតិភូគណបក្សស្ថាបនិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសមាសភាពចំនួនបីរូប ដែលក្នុងនោះមួយរូបជាប្រធានប្រតិភូ មានឋានៈស្មើទេសរដ្ឋមន្ត្រី មួយរូបជាអនុប្រធានប្រតិភូ មានឋានៈស្មើរដ្ឋមន្ត្រី និងមួយរូបទៀតជាសមាជិកប្រតិភូ មានឋានៈស្មើរដ្ឋលេខាធិការ។

ក្រៅពីគណបក្សស្ថាបនិក ប្រតិភូគណបក្សនយោបាយផ្សេងទៀតដែលជាសមាជិកនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសមាសភាពចំនួនពីររូប ដែលក្នុងនោះមួយរូបជាប្រធានប្រតិភូ មានឋានៈស្មើទេសរដ្ឋមន្ត្រី និងមួយរូបទៀតជាអនុប្រធានប្រតិភូ មានឋានៈស្មើរដ្ឋមន្ត្រី។

ប្រតិភូគណបក្សនយោបាយម្នាក់ៗនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានតួនាទីជាទីប្រឹក្សារាជរដ្ឋាភិបាលផងដែរ។

ប្រតិភូគណបក្សនយោបាយ ត្រូវតែជាប្រធាន អនុប្រធាន ឬអគ្គលេខាធិការនៃគណបក្សនយោបាយនីមួយៗ។ ក្នុងករណីគណបក្សនយោបាយចាត់តាំងប្រតិភូរបស់ខ្លួនដែលជាឥស្សរជនផ្សេងពីនេះ ត្រូវមានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី។



តេឡេក្រាម ឯកសារផ្លូវការណ៍ - https://t.me/oa_channel

សមាសភាពនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

ប្រធានប្រតិភូគណបក្សស្ថាបនិកនីមួយៗអាចមានជំនួយការពីររូប ដែលមួយរូបមានឋានៈស្មើអគ្គនាយក និងមួយរូបទៀតមានឋានៈស្មើអគ្គនាយករង។ ប្រធានប្រតិភូគណបក្សនយោបាយផ្សេងទៀតក្រៅពីគណបក្សស្ថាបនិក អាចមានជំនួយការមួយរូប មានឋានៈស្មើអគ្គនាយក។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

**មាត្រា៦ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់រៀងរាល់មួយខែម្តង តាមការកោះប្រជុំរបស់ប្រធានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

ប្រធានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវជ្រើសចេញពីប្រធានប្រតិភូគណបក្សនយោបាយ ដោយត្រូវអនុវត្តតាមគោលការណ៍ប្តូរវេនរៀងរាល់មួយខែម្តង ដោយយកតាមលំដាប់លេខរៀងគណបក្សនយោបាយនៅក្នុងសន្លឹកឆ្នោតដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់គណបក្សស្ថាបនិក និងលំដាប់លេខរៀងជាបន្តបន្ទាប់ តាមកាលបរិច្ឆេទនៃការសម្រេចយល់ព្រមរបស់នាយករដ្ឋមន្ត្រីចំពោះគណបក្សនយោបាយផ្សេងទៀតដែលមិនមែនជាគណបក្សស្ថាបនិក។

**មាត្រា៧ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់ជាមួយនាយករដ្ឋមន្ត្រីរៀងរាល់ប្រាំមួយខែម្តង តាមការកោះប្រជុំរបស់នាយករដ្ឋមន្ត្រី។

ក្នុងករណីចាំបាច់ ក្នុងចន្លោះប្រាំមួយខែ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់អាចជួបប្រជុំពិគ្រោះ និងផ្លាស់ប្តូរយោបល់ ជាវិសាមញ្ញជាមួយនាយករដ្ឋមន្ត្រី តាមការស្នើសុំពីប្រតិភូគណបក្សនយោបាយចំនួន ១/៣ (មួយភាគបី) យ៉ាងតិច។

ក្នុងករណីមានធុរៈដែលមិនអាចចូលរួមប្រជុំបាន នាយករដ្ឋមន្ត្រីអាចចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ជាតំណាងដឹកនាំកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

## ជំពូកទី៤
## ភារកិច្ចរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

**មាត្រា៨ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បំពេញភារកិច្ចរបស់ខ្លួនក្រៅក្របខណ្ឌសភា ក្នុងការផ្តល់ធាតុចូលដោយផ្ទាល់ជូនរាជរដ្ឋាភិបាលក្នុងន័យស្ថាបនា សំដៅលើកស្ទួយប្រសិទ្ធភាពការងាររបស់ស្ថាប័នរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការបម្រើប្រជាជន និងសង្គមជាតិ។

**មាត្រា៩ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានភារកិច្ចចម្បងធំៗ៖

១- ផ្តួចផ្តើមគំនិត ឬផ្តល់យោបល់លើការរៀបចំគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ក្រៅក្របខណ្ឌសភា ដូចមានចែងក្នុងមាត្រា១០ នៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២- ផ្តួចផ្តើមគំនិតតាក់តែង ឬផ្តល់យោបល់លើការរៀបចំធ្វើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមករាជរដ្ឋាភិបាល ហើយផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់រាជរដ្ឋាភិបាល ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីធ្វើច្បាប់ដែលកំពុងស្ថិតក្នុងក្របខណ្ឌអំណាចនីតិប្រតិបត្តិ ដូចមានចែងក្នុងមាត្រា១១ និងមាត្រា១២ នៃព្រះរាជក្រឹត្យនេះ។

៣- តាមដានដំណើរការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងផ្តល់អនុសាសន៍កែលម្អភាពអសកម្ម និងភាពមិនប្រក្រតី ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា១០ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសិទ្ធិផ្តួចផ្តើមរៀបចំគោលនយោបាយនានា ដើម្បីស្នើជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច។

មុនដាក់ចូលក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី គោលនយោបាយនានារបស់រាជរដ្ឋាភិបាលអាចត្រូវបានដាក់ឆ្លងការប្រជុំផ្តល់មតិពីឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ជាមុនតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**មាត្រា១១ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសិទ្ធិផ្តួចផ្តើមគំនិតតាក់តែងរៀបចំធ្វើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្នើជូននាយករដ្ឋមន្ត្រី ដើម្បីពិនិត្យ និងចាត់ចែងប្រគល់ជូនរដ្ឋមន្ត្រីក្រសួង ឬរដ្ឋលេខាធិការដ្ឋានដែលមានសមត្ថកិច្ចជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យ សិក្សា និងផ្តល់យោបល់ជូននាយករដ្ឋមន្ត្រីសម្រេច។

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់អាចស្នើ ឬផ្តល់យោបល់ជូននាយករដ្ឋមន្ត្រីអំពីតម្រូវការចាំបាច់ជាក់ស្តែងនៃការរៀបចំតាក់តែងធ្វើវិសោធនកម្មច្បាប់ ឬកែសម្រួលលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជូននាយករដ្ឋមន្ត្រីពិនិត្យនិងបញ្ជូនទៅរដ្ឋមន្ត្រីក្រសួង ឬរដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ។

**មាត្រា១២ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់អាចផ្តល់មតិលើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលរៀបចំដោយក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ជូនមកនាយករដ្ឋមន្ត្រីឱ្យបានមុនពេលប្រជុំគណៈរដ្ឋមន្ត្រីដែលនឹងពិភាក្សាលើរបៀបវារៈនេះ។

**មាត្រា១៣ ..**

ដើម្បីជាមូលដ្ឋានយល់ដឹងសម្រាប់លើកស្ទួយប្រសិទ្ធភាពនៃការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា១០ មាត្រា១១ និងមាត្រា១២ នៃព្រះរាជក្រឹត្យនេះ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មានសិទ្ធិសុំទៅរដ្ឋមន្ត្រីក្រសួង ឬរដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ ធ្វើបទបង្ហាញជូនឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បាន។ ក្នុងករណីមានធុរៈ រដ្ឋមន្ត្រីអាចចាត់តំណាងដើម្បីធ្វើបទបង្ហាញជូនឧត្តមក្រុមប្រឹក្សាពិគ្រោះនិង



តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**មាត្រា១៤ ..**

ក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា៩ កថាខណ្ឌ៣ នៃព្រះរាជក្រឹត្យនេះ ប្រតិភូគណបក្សនយោបាយនីមួយៗមានសិទ្ធិពេញលេញក្នុងការចុះធ្វើការតាមដានដំណើរការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅជួយរកឱ្យឃើញនូវភាពអសកម្ម ភាពមិនប្រក្រតី អំពើពុករលួយ និងការរំលោភបំពានអំណាចពីសំណាក់បុគ្គលជាមន្ត្រី ឬអាជ្ញាធរគ្រប់ផ្នែក និងគ្រប់ថ្នាក់។

ក្នុងការចុះបំពេញការងារនេះ សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ប្រើប្រាស់តួនាទីជាទីប្រឹក្សារាជរដ្ឋាភិបាល ដើម្បីឱ្យដំណើរការការងារប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

**មាត្រា១៥ ..**

សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់អាចដាក់លទ្ធផលនៃការងារនេះ ដូចមានចែងក្នុងមាត្រា១៤ នៃព្រះរាជក្រឹត្យនេះ ទៅក្នុងរបៀបវារៈពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចប្រជុំណាមួយរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ និង/ឬ ដាក់ជូននាយករដ្ឋមន្ត្រីផ្ទាល់តែម្តងក៏បាន ដើម្បីពិនិត្យ និងសម្រេច។

ក្នុងកិច្ចប្រជុំលើរបៀបវារៈណាមួយ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់អាចលើកយោបល់កែលម្អអំពីភាពអសកម្ម ឬភាពមិនប្រក្រតីជូននាយករដ្ឋមន្ត្រីបាន។

## ជំពូកទី៥
## លេខាធិការដ្ឋាន

**មាត្រា១៦ ..**

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានលេខាធិការដ្ឋានមួយនៅក្រោមនាយករដ្ឋមន្ត្រី។ លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ដឹកនាំផ្ទាល់ដោយប្រធានមួយរូប ដែលត្រូវបានចាត់តាំងដោយនាយករដ្ឋមន្ត្រី។

**មាត្រា១៧ ..**

គណបក្សនយោបាយដែលចូលរួមក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវចាត់តាំងមន្ត្រីរបស់ខ្លួនចំនួនមួយរូប មកបម្រើការក្នុងលេខាធិការដ្ឋាន មានឋានៈស្មើអនុរដ្ឋលេខាធិការ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ប្រភពធនធាន និងចំណាយសម្រាប់កិច្ចដំណើរការ

**មាត្រា១៨ ..**

ការចំណាយសម្រាប់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងខ្ទង់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់ តាមនីតិវិធីច្បាប់ ជាធរមាន នូវមូលនិធិដែលបានពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១៩ ..**

សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ សមាសភាពនៃលេខាធិការដ្ឋាន និងជំនួយការរបស់ប្រធានប្រតិភូគណបក្សនយោបាយ ទទួលបានប្រាក់បំណាច់មុខងារ និងរបបឧបត្ថម្ភផ្សេងៗទៀតសម្រាប់ការបំពេញការងាររបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ សមាសភាពនៃលេខាធិការដ្ឋាន និងជំនួយការរបស់ប្រធានប្រតិភូគណបក្សនយោបាយ មិនអាចទទួលបានប្រាក់បំណាច់មុខងារលើសពីមួយបានឡើយ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ ..**

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ១០កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០២៣

នស/រកត.០៨២៣.១០៩១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**



គេហទំព័រឯកសារផ្លូវការ - https://t.me/oa_channel